ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ក្រុមហ៊ុនមេធាវី តម្រាច្បាប់
LEGAL CODE LAW FIRM
លេខ: ១២២/ត.រ.ច/២១

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការបំពេញការងាររបស់ក្រុមហ៊ុនមេធាវី តម្រាច្បាប់ ក្នុងអំឡុងពេលបិទខ្ទប់ ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្ដាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

**យោង** ៖ សេចក្ដីសម្រេច លេខ: **៥០ សសរ** ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ ស្ដីពីការកែសម្រួលវិធានការដែលត្រូវអនុវត្តក្នុងអំឡុងពេលបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និង ក្រុងតាខ្មៅនៃខេត្តកណ្ដាល ដើម្បីទប់ស្កាត់ការចម្លងរាលដាលនៃជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាលកម្ពុជា ។

ដើម្បីចូលរួមអនុវត្តសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល ក្នុងអំឡុងពេលបិទខ្ទប់រាជធានីភ្នំពេញ ដែលបានកំណត់ចន្លោះពីថ្ងៃទី១៥ ដល់ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ ឱ្យមានប្រសិទ្ធភាព និង ដើម្បីបញ្ចៀសនូវការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បន្តទៀត **ក្រុមហ៊ុនមេធាវី តម្រាច្បាប់** សូមជម្រាបជូនដំណឹងដល់ សាធារណជន ក្រុមហ៊ុនជាដៃគូ អតិថិជន និងស្ថាប័នពាក់ព័ន្ធមេត្តាជ្រាបថា៖ រាល់ការផ្ដល់សេវាកម្មច្បាប់តាមរយៈជំនួបផ្ទាល់ ពាក់ព័ន្ធនឹងការប្រឹក្សាយោបល់ដោយផ្ទាល់ ឬ ការចុះកិច្ចព្រមព្រៀងផ្សេងៗ រួមទាំងការចូលរួមកិច្ចនីតិវិធីរបស់តុលាការជាអាទិ៍ នីតិវិធីសាកសួរ នីតិវិធីសវនាការ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងកិច្ចនីតិវិធីផ្សេងៗ ក្រុមហ៊ុនយើងខ្ញុំនឹងសម្រេចធ្វើការស្នើសុំពន្យារពេល តាមការឯកភាព ឬ ស្នើសុំដោយអតិថិជន ។

ជាអញ្ញត្រកម្ម ចំពោះចំណាត់ការរបស់មេធាវីនៅក្នុងកិច្ចនីតិវិធីក្រៅប្រព័ន្ធតុលាការ ឬ កិច្ចនីតិវិធីនៃសំណុំរឿងនៅក្នុងប្រព័ន្ធតុលាការ ដែលអតិថិជនស្នើសុំជំនួយផ្នែកច្បាប់ជាចាំបាច់ និងបន្ទាន់បំផុត ដោយខានពុំបាននោះ ក្រុមហ៊ុនយើងខ្ញុំនឹងផ្ដល់សេវាកម្មទៅតាមលទ្ធភាព ផ្អែកលើការពិនិត្យស្ថានភាពជាក់ស្ដែងដោយប្រធានក្រុមហ៊ុន ។ ទន្ទឹមនឹងនេះ ក្រុមហ៊ុនយើងខ្ញុំនៅតែបន្តផ្ដល់ជូនសេវាកម្មចាំបាច់មួយចំនួនទៀត ដោយប្រតិបត្តិការតាមរយៈប្រព័ន្ធអេឡិចត្រូនិក (Online) ជាអាទិ៍ ការប្រឹក្សាយោបល់ ការរៀបចំលិខិតជូនដំណឹង ការរៀបចំតាក់តែងកិច្ចព្រមព្រៀង និងលិខិតស្នាមគតិយុត្តផ្សេងៗ រួមទាំងបន្តចំណាត់ការនៃការស្នើសុំផ្សេងៗ ទៅតាមភាពចាំបាច់របស់អតិថិជនទៅកាន់ស្ថាប័នពាក់ព័ន្ធ ។ ចំពោះ ស្ថានភាពចាំបាច់ដែលអតិថិជនត្រូវការជំនួយផ្នែកច្បាប់បន្ទាន់ និង ទាមទារឱ្យមានកិច្ចជំនួបផ្ទាល់ជាមួយអតិថិជន ក្រុមហ៊ុនអាចនឹងសម្រេចធ្វើការណាត់ជួបតាមរបៀបនៃការអនុវត្តនូវវិធានការសុខាភិបាល **៣ ការពារ ៣ កុំ** យ៉ាងម៉ឺងម៉ាត់ និង តឹងរឹងបំផុត ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ក្រុមហ៊ុនជាដៃគូ អតិថិជន និងស្ថាប័នពាក់ព័ន្ធមេត្តាជ្រាបជាព័ត៌មាន និង ចូលរួមអនុវត្តនូវសេចក្ដីសម្រេច លេខ: ៥០ របស់រាជរដ្ឋាភិបាលដូចយោងខាងលើ ដើម្បីប្រយុទ្ធប្រឆាំង ការពារការរីករាលដាលនៃជំងឺកូវីដ-១៩ ។

ថ្ងៃច័ន្ទ ៨ កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១
**ក្រុមហ៊ុនមេធាវី តម្រាច្បាប់**

LEGAL CODE LAW FIRM

ផ្ទះលេខ ១៨១ ផ្លូវ ១៥០ សង្កាត់ទឹកល្អក់ទី ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
Tel: (+855) 86 262 630 / 92 299 934
Address: #181, St.150, Sangkat Tuek L'ak Ti Pir, Khan Toul Kork, Phnom Penh.
Email:info@legalcodecambodia.com